**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ៣២នាក់ និងករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ០១នាក់
## នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **១៩៦នាក់** (ស្មើនឹង ៨១,៦៧% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះមានស្រី ៤២នាក់ និងបុរស ១៥៤នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៤០នាក់** (ស្រ្តី ៤៦នាក់ និងបុរស ១៩៤នាក់។
- អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ មានចំនួនសរុប **៤២នាក់៖**
  - នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានចំនួន ០២នាក់ (ស្រ្តី ០១នាក់ និងបុរស ០១នាក់)
  - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញមានចំនួន ៣៤នាក់ (ស្រ្តី ០២នាក់ និងបុរស ៣២នាក់)
  - នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺមានចំនួន ០៦នាក់ ជាបុរស
- អ្នកសម្រាកព្យាបាលនៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា៖ ស្រ្តីជនជាតិអាមេរិកកាំង **០១នាក់** និងបុរសជនជាតិអាមេរិកកាំង **០១នាក់**។

**២. ករណីជាសះស្បើយ៖** បុរសជនជាតិខ្មែរចំនួន ២៩នាក់ និងបុរសជនជាតិឥណ្ឌូណេស៊ី ចំនួន ០៣នាក់

**២.១.អ្នកជាសះស្បើយ ដែលធ្វើដំណើរមកពីប្រទេសរុស្ស៊ី និងអេហ្ស៊ីប ចំនួន ១៥នាក់**

-បុរសអាយុ ២៦ឆ្នាំ មានអាសយដ្ឋាននៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

- បុរសអាយុ ៣១ឆ្នាំ មានអាសយដ្ឋាននៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

- បុរសអាយុ ២៥ឆ្នាំ មានអាសយដ្ឋាននៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

- បុរសអាយុ ២៨ឆ្នាំ មានអាសយដ្ឋាននៅភូមិថ្កូវក្រើង ឃុំថ្កូវ ស្រុកមេសហេក ខេត្តស្វាយរៀង

- បុរសអាយុ ២៨ឆ្នាំ មានអាសយដ្ឋាននៅឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង

- បុរសអាយុ ២៩ឆ្នាំ មានអាសយដ្ឋាននៅផ្ទះលេខ ១០E ផ្លូវ២៧១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

**សម្គាល់៖** ពួកគាត់ទាំង ០៦នាក់ខាងលើ ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសរុស្ស៊ី បន្តជើងហោះហើរនៅប្រទេសម៉ាឡេស៊ីមកកម្ពុជា ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បុរសអាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅខេត្តពោធិ៍សាត់
- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅស្រុកសៀមរាបខេត្តសៀមរាប
- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅខណ្ឌដូនពេញ រាជធានីភ្នំពេញ
- បុរសអាយុ ២៩ឆ្នាំ មានអាស័យដ្ឋាននៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
- បុរសអាយុ ៣៨ឆ្នាំ មានអាស័យដ្ឋាននៅស្រុកសៀមរាប ខេត្តសៀមរាប
- បុរសអាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង
- បុរសអាយុ ២៣ឆ្នាំ មានអាស័យដ្ឋាននៅសង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ
- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅស្រុកអង្គរបូរី ខេត្តតាកែវ
- បុរសអាយុ ៣០ឆ្នាំ មានអាស័យដ្ឋាននៅខណ្ឌចំការមន រាជធានីភ្នំពេញ

**សម្គាល់៖** បុរសជនជាតិខ្មែរទាំង ០៩នាក់ខាងលើ ជាអ្នកធ្វើដំណើរមកពីប្រទេសរុស្ស៊ី និងអេហ្ស៊ីប បន្តជើងហោះហើរនៅប្រទេសម៉ាឡេស៊ី ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ។

**២.២.អ្នកជាសះស្បើយ ដែលធ្វើដំណើរមកពីប្រទេសម៉ាលី ចំនួន ០២នាក់**

- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋានៅភូមិ២ ឃុំកោះខ្នុល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ៤៧ឆ្នាំ មានអាស័យដ្ឋានៅភូមិដំណាក់ចង្អើរ ខេត្តកែប

**សម្គាល់៖**ពួកគាត់ទាំង ០២នាក់ខាងលើ ជាក្រុមមួកខៀវអង្គការសហប្រជាជាតិរបស់កម្ពុជា ដែលបានវិលត្រឡប់មកពីប្រទេសម៉ាលី ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**២.៣.អ្នកជាសះស្បើយ ដែលធ្វើដំណើរមកពីប្រទេសអារ៉ាប់ប៊ីសាអូឌីត ចំនួន ០៨នាក់**

- បុរសអាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅសង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិស្វាយឃ្លាំង ឃុំទី៥ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិកំពង់ត្រឡាច ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
- បុរសអាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ
- បុរសអាយុ ២៩ឆ្នាំ មានអាស័យដ្ឋាននៅភូមិបាតដីក្រោម ឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិបេងថ្មី ឃុំសេដា ស្រុកតំបែរ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ៣៣ឆ្នាំ មានអាស័យដ្ឋាននៅភូមិ៦ ឃុំកោះខ្នុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅភូមិជើងឡូង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ

**សម្គាល់៖** ពួកគាត់ទាំង ០៨នាក់ ខាងលើ ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសអារ៉ាប់ប៊ីសាអូឌីត បានបន្តជើងហោះហើរពីប្រទេសម៉ាឡេស៊ីមកកម្ពុជា ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**២.៤. អ្នកជាសះស្បើយ ដែលធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី ចំនួន ០៧នាក់**

- បុរសអាយុ ២៣ឆ្នាំ មានអាស័យដ្ឋាននៅភូមិអន្លង់ក្រមួន ឃុំស្រែឫស្សី ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង (ក្រសួងសុខាភិបាល ស្នើសុំកែតម្រូវអាយុ និងដាក់អាស័យដ្ឋាននេះវិញ ដោយសារសាមីខ្លួនបានផ្តល់ព័ត៌មានមានការផ្លាស់ប្តូរ ដែលនៅពេលរកឃើញមានវិជ្ជមានវីរុសកូវីដ-១៩ នោះ គាត់បានជម្រាបថា មានអាយុ ២៦ឆ្នាំ និងមានអាស័យដ្ឋាន នៅភូមិទ្រា ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ)
- បុរសអាយុ ២៣ឆ្នាំ មានអាស័យដ្ឋាននៅភូមិអូត្រាវ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**សម្គាល់ ៖** បុរសទាំង ០២នាក់ខាងលើ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី មកកម្ពុជា បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

- បុរសជនអាយុ ២៦ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពុងចាម
- បុរសជនអាយុ ២៥ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ

**សម្គាល់៖** ពួកគាត់ទាំង ០២នាក់ខាងលើ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ីតាមជើងហោះហើរមកកម្ពុជា ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

- បុរសជនជាតិឥណ្ឌូណេស៊ីអាយុ ៣៧ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅបណ្តោះអាសន្ននៅសណ្ឋាគារ មួយក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បុរសជនជាតិឥណ្ឌូណេស៊ីអាយុ ៣២ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅបណ្តោះអាសន្ននៅសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បុរសជនជាតិឥណ្ឌូណេស៊ីអាយុ ៣៥ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅបណ្តោះអាសន្ននៅសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

**សម្គាល់៖** ពួកគាត់ទាំង ០៣នាក់ខាងលើនេះ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី ឆ្លងកាត់បន្តជើងហោះហើរនៅប្រទេសម៉ាឡេស៊ី ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

## ៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០១នាក់

- បុរសជនជាតិខ្មែរអាយុ ៥៧ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅភូមិត្រពាំងឈូក សង្កាត់ការកោប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានលទ្ធផលតេស្ត វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ បច្ចុប្បន្ន ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**សម្គាល់៖** បុរសរូបនេះ ជាអ្នកធ្វើដំណើរមកពីសហរដ្ឋអាមេរិក ដោយបានបន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកកម្ពុជា ដោយមានអ្នកដំណើរសរុបចំនួន ១១២នាក់ (ស្រី ៤៣នាក់ កុមារី ១១នាក់ កុមារ ០៧នាក់ និងបុរស ៥១នាក់) ដែលបានចាកចេញដំណើរមកពីប្រទេស ៖

- កូរ៉េខាងត្បូង ៣៧នាក់ (ជនជាតិកូរ៉េ ២០នាក់ និងជនជាតិខ្មែរ ១៧នាក់)
- សហរដ្ឋអាមេរិក ៣៨នាក់ (ជនជាតិខ្មែរ ០៩នាក់ ជនជាតិចិន ០១នាក់ ជនជាតិម៉ិកស៊ិក ០១នាក់ និង ជនជាតិអាមេរិកកាំង ២៧នាក់)
- កាតា ០៤នាក់ (ជនជាតិស្វីស ០៣នាក់ និងជនជាតិខ្មែរ០១នាក់)
- ស៊ុយអែត ០១នាក់ (ជនជាតិថៃ )
- អូស្ត្រាលី ០១នាក់ (ជនជាតិអូស្ត្រាលី)
- អេមីរ៉ាត់អារ៉ាប់រួម ០១នាក់ (ជនជាតិខ្មែរ)
- អាល្លឺម៉ង់ ០២នាក់ (ជនជាតិអាល្លឺម៉ង់)
- ហូឡង់ ១៦នាក់ (ជនជាតិបែលហ្ស៊ិក ០២នាក់ ជនជាតិហូឡង់ ០៣នាក់ អង្គការសហប្រជាជាតិ ០២នាក់ជនជាតិខ្មែរ ០២នាក់ ជនជាតិអង់គ្លេស ០៥នាក់ និងជនជាតិអេស្ប៉ាញ ២នាក់)
- កាណាដា ១២នាក់ (ជនជាតិខ្មែរ ០១នាក់ ជនជាតិហ្វីលីពីន ០១នាក់ ជនជាតិបារាំង ០១នាក់ និងជនជាតិកាណាដា ០៩នាក់) ។

រីឯអ្នកដំណើរចំនួន ១១១នាក់ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័ក ចំនួន ១៤ថ្ងៃ ៖ នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេចហ៊ុន សែនភ្នំពេញថ្មី មានចំនួន ០៧នាក់ នៅសណ្ឋាគារមួយក្នុង រាជធានីភ្នំពេញចំនួន ៨៩នាក់ នៅសណ្ឋាគារមួយទៀតក្នុងរាជធានីភ្នំពេញ ចំនួន ០១នាក់ នៅស្ថានកុងស៊ុលស៊ុីសប្រចាំ កម្ពុជា ចំនួន ០៣នាក់ នៅទីស្នាក់ការ UNDP ចំនួន ០៤នាក់ និងនៅស្ថានទូតអាមេរិកប្រចាំកម្ពុជា ចំនួន ០៧នាក់។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុម គ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខ ភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំ បំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញ យកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ១៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩